អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

## សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត

# សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចលើកដំបូងលើ ភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២

**រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ -** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានចាប់ផ្តើមចេញដីកាសម្រេចលើភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន **៣៩៨៨** ដែលបានដាក់នៅក្នុងក្របខណ្ឌនៃសំណុំរឿង០០២ ។

មុននឹងឈានដល់ការចេញដីកាសម្រេចទាំងនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើការវិភាគយ៉ាងម៉ត់ចត់លើសំណើសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ក៏ដូចជាទម្រង់បែបបទសុំដាក់ព័ត៌មានបន្ថែមចំនួន **២៥០០** ដែលឯកសារទាំងនេះមានការ រៀបរាប់យ៉ាងលម្អិតអំពីអង្គហេតុដែលចោទប្រកាន់ និងត្រូវបានដាក់ដោយអ្នកដាក់ពាក្យសុំនៅក្នុងថិរវេលាកំណត់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០។

អ.វ.ត.ក. គឺថិតនៅក្នុងចំណោមតុលាការអន្តរជាតិ ឬអន្តរជាតូបនីយកម្មដំបូងគេ ដែលទទួលស្គាល់តួនាទីសកម្មរបស់ជនរងគ្រោះក្នុងនាមជាភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ដើម្បីអាចទទួលបាននូវជនរងគ្រោះច្រើននៅក្នុងសំណុំរឿង០០២ វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្ម និងបានចែងថា ភាពអាចទទួលយកបាន នៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវសម្រេចនៅក្នុងដំណាក់កាលស៊ើបសួរ ហើយយ៉ាងយូរបំផុតនៅពេលចេញដីកាដំណោះស្រាយ។ ហេតុដូច្នេះ នៅក្នុងពេលវេលាដ៏តិចតួចបំផុត សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការវិភាគយ៉ាងល្អិតល្អន់លើសំណើសុំនីមួយៗ ដែលមានចំនួនដ៏ច្រើនលើសលប់។ សហចៅក្រមស៊ើបអង្កេតបានព្យាយាមធ្វើការពិនិត្យដោយសម្របទៅតាមបរិបទកម្ពុជា ជាពិសេសបញ្ហាលំបាកដែលចោទឡើងចំពោះជនរងគ្រោះក្នុងការផ្តល់នូវភ័ស្តុតាងសត្យានុម័តអំពីព្យសនកម្មរបស់ពួកគេ។

ដោយពិនិត្យឃើញពីតម្រូវការនៃការសម្របសម្រួលផ្នែកព័ត៌មាន និងតម្រូវការនៃការផ្តល់នូវអ្នកតំណាងតាមផ្លូវច្បាប់សម្រាប់ជនរងគ្រោះនិងអ្នកដាក់ពាក្យប្តឹង សហចៅក្រមស៊ើបអង្កេតបានសម្រេចធ្វើដីកាសម្រេចលើភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅតាមទីលំនៅរបស់អ្នកដាក់ពាក្យសុំ ដូចដែលមានបង្ហាញនៅលើទម្រង់បំពេញព័ត៌មានរបស់ពួកគេ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាសម្រេចសម្រាប់ខេត្តនីមួយៗ នៅទូទាំង២៤ខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាដីកាសម្រេចមួយទៀតសម្រាប់អ្នកដែលមានទីលំនៅនៅឯបរទេស។ ដោយយោងទៅលើចំនួនជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដីកាសម្រេចទាំងនេះនឹងត្រូវចេញជាបន្តបន្ទាប់គ្នា។

ដោយពិនិត្យឃើញអំពីសារសំខាន់សម្រាប់ជនរងគ្រោះក្នុងការទទួលបាននូវជំនួយផ្នែកច្បាប់ ដោយមានជំនួយពីអង្គភាពគាំទ្រជនរងគ្រោះ និងដោយមានការសហការជាមួយនឹងក្រុមមេធាវី សហចៅក្រមស៊ើបអង្កេតបានរៀបចំនូវការតំណាងផ្លូវច្បាប់ជារួមមួយ ដើម្បីធានាបានថាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូបទទួលបាននូវមេធាវីតំណាង ដែលអាចឲ្យគាត់មានលទ្ធភាពអនុវត្តសិទ្ធិចូលរួមក្នុងដំណើរការក្តីប្រកបដោយប្រសិទ្ធិភាព។

សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការចូលរួមរបស់ជនរងគ្រោះនៅក្នុងនីតិវិធីតុលាការ គឺជាចំណុចស្នូលរបស់ អ.វ.ត.ក.។ ទោះបីយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវធ្វើការរំលឹកថា សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តច្បាប់ជាធរមាន ដូច្នេះ ដើម្បីអាចទទួលបាននូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវតែបង្ហាញថា គាត់បានទទួលរងនូវព្យសនកម្មជាលក្ខណៈបុគ្គលដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុដែលប្តឹងដោយសហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម (សូមមើលសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩)។ អាស្រ័យហេតុនេះ សំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននឹងត្រូវប្រកាសបដិសេធមិនទទួលយកជាចាំបាច់ ដែលការណ៍នេះនឹងមិនប៉ះពាល់ដល់ការទទួលស្គាល់ឋានៈជាជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំនោះឡើយ។ ដូច្នេះ រាល់ខ្លឹមសារទាំងអស់ដែលមានរៀបរាប់នៅក្នុងសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានរក្សាទុកនៅក្នុងសំណុំរឿងក្រោមទម្រង់ជាពាក្យបណ្តឹង រួមជាមួយនឹងពាក្យបណ្តឹងជាង ៤០០០ ផ្សេងទៀតដែលបានដាក់ដោយផ្ទាល់ជាមួយនឹង

សហព្រះរាជអាជ្ញា។ ដូច្នេះ ឯកសារទាំងនេះអាចត្រូវបានចូលមើលដោយគ្រប់ភាគីទាំងអស់ ដែលនៅក្នុងករណីចាំបាច់ អាចពិនិត្យមើលវាដើម្បីសំអាងនៅក្នុងការជំនុំជម្រះ។

ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបើកផ្លូវសម្រាប់ប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងថិរវេលាកំណត់ចំនួន១០ថ្ងៃ គិតចាប់ពីថ្ងៃនៃការជូនដំណឹងអំពីដីកាសម្រេច ហើយអ្នកធ្វើបណ្តឹងឧទ្ធរណ៍អាចមានមេធាវីជាជំនួយ។

សហចៅក្រមស៊ើបអង្កេតសូមរំឭកថា សំណងដែលដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងទទួលបានមិនមែនជាសំណងហិរញ្ញវត្ថុនោះទេ ម្យ៉ាងវិញទៀត សេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាអំពីប្រយោជន៍របស់ជនរងគ្រោះទាំងអស់ ទោះបីជាបានឬមិនបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬសំណើសុំត្រូវបានទទួលយកឬបដិសេធមិនទទួលយកក៏ដោយ។ សហចៅក្រមស៊ើបអង្កេតសង្ឃឹមថា ជនរងគ្រោះកម្ពុជាទាំងអស់នឹងមានការយោគយល់ និងទទួលស្គាល់នូវស្ថានភាពនីតិវិធីដែលមានចរិតលក្ខណៈពិសេសនៃ អ.វ.ត.ក. ជាក់ជាមិនខាន៕